ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

លេខ ១១

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណឺម៉ង់
គ្រិ. ឆ្នាំ ១៩៣១
ពុ.ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

២- អនុមោទនវិធី អាចារ្យ សុក នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង ព្រះគ្រូសំសត្ថា ណាត ចាងហ្វាងរងសាលាបរិយត្តិជាន់ខ្ពស់ពាក់ពិនិត្យផ្ទៀងផ្ទាត់ . . . . . . . . . .

"មិលិន្ទបញ្ហា និងនុអមោទនាវិធី មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយឡែកហើយ" . . . . . . .

៣- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . ៣២៧

# វិធីគួបតែងព្រះពុទ្ធសាសនាឲ្យចម្រើនឡើង
# នៅក្នុងនគរកម្ពុជា

ដើម្បីនឹងបានតបស្នងគុណសត្វា របស់ព្រះរាជបណ្ណាល័យ ដែលបាន ផ្សាយធម៌និងវិន័យច្រើនមុខនៅនានគរខេមរៈនេះ ជាសេចក្តីប្រយោជន៍ ធំដល់កល្យាណសប្បុរសទាំងអស់គ្នា ខ្ញុំសូមអធិប្បាយជាថែបខ្លីៗ អំពី ព្រះពុទ្ធសាសនា ក្នុងនគរកម្ពុជាយើងនេះ ។

បពិត្រសាធុជនទាំងឡាយ សាសនាព្រះឈ្មោះមារជាម្ចាស់ក្នុងបុរី យើងសព្វថ្ងៃនេះ ពុំបានរុងរឿងវិសេសប៉ុន្មានទេ ព្រះពុទ្ធសាសនា ដែលបានចំរុងចំរើនរុងរឿងឡើង ដោយសារតែពុទ្ធបរិស័ទឈឺឆ្អាលជួយ ឧបត្ថម្ភគាំទ្រ គោរពប្រតិបត្តិធម៌និងវិន័យត្រឹមត្រូវគ្រប់តាមពុទ្ធោវាទ សម នឹងសេចក្តីដែលមានក្នុងបច្ឆិមពុទ្ធវចនៈដែលព្រះអណាវញ្ញាណបានប្រាប់ ចំពោះនឹងព្រះអានន្ទ នៅក្នុងនគរកុសិនារា ។

ខ្ញុំមានចិត្តសង្ស័យណាស់ ហេតុដូចម្តេចបានជានគរខ្មែរយើង សាសនាព្រះភគវន្តមុនីសាស្តាពុំបានប្រសើរប៉ុន្មាន តាមសេចក្តីអត្ថនោ- មតិកាត់ប្រមាណស្មានរបស់ខ្ញុំ យល់ឃើញថាដូចនេះ ៖

ប្រការ១— ពួកប្រាជ្ញរាជបណ្ឌិតជាតិខ្មែរមានតិចណាស់

ប្រការ២— ពួកប្រាជ្ញរាជបណ្ឌិតនោះ ពុំមានធម៌សាមគ្គីសមគ្គា

រស់អាស្រ័យគ្នាទៅវិញទៅមក ក្នុងកិរិយាសម្តែងបែងអធិប្បាយផ្សាយធម៌និងវិន័យ ។

ប្រការ៣– ពុទ្ធសាសនិកជនមានទិដ្ឋិ មានប្រកាន់អ្នកគាំងជាខ្លួន សិក្សាធម៌វិន័យត្រឹមត្រូវហើយ តាមបន្ទាប់របស់គ្រូអាចារ្យអំពីដើមរៀងមក ។

ប្រការ៤– ពុទ្ធសាសនិកជននោះ បែកទៅជាពួកជាកងជានិកាយ ពុំមានចិត្តវិស្សាសះរាប់អានគ្នា ហេតុទាំង ៤ ប្រការនេះជាប្រធាន ធ្វើឲ្យសាសនាព្រះអនាវរញាណពុំចម្រើនកើនឡើង ឲ្យជាកិយ្យាភាពក្រៃលែងតទៅទៀតបាន ។

សប្បុរសគប្បីយល់ថា តម្រិះវិជ្ជា កើតមានមកអំពីសូត្ររៀនដូចមានឧបុកណាភាសិតមួយថា ចេះមកពីរៀន មានមកពីរក ក្នុងនគរខ្មែរយើងមានសាលាបរិយត្តិបាលីមួយ ជាទីធ្វើឲ្យអ្នកប្រាជ្ញបរិបូណ៌ច្រើនឡើង ដើម្បីនឹងបានជួយពត់តម្រង់ព្រះពុទ្ធសាសនា ព្រះវិន័យបិដកសឹងមានក្នុងមន្ទីរនោះគ្រប់គ្រាន់ល្មមប្រើការបាន ដោយងាយស្រួលណាស់ គួរយើងទាំងអស់គ្នាសូត្ររៀនព្រះបរិយត្តិឲ្យចេះដឹង ប្រឹងជួយសាលាបាលីដែលជាអាយុព្រះពុទ្ធសាសនា ជាពរកេរ្តិ៍របស់ព្រះករុណាបរមពជានុគោដ្ឋ ជាម្ចាស់ជីវិតយើង បុប្ផាផ្កាទាំងឡាយស្រស់ល្អស្រួលក្នុងវេលាដែលដើមវុក្ខាមានជីវិតរស់នៅ បើប្រសិនណាជាដើមវុក្ខាត្រូវកំដៅ

ព្រះអាទិត្យខ្លាំងពេក ស្ងាប់ទៅកាលណាបុប្ផាទាំងឡាយនោះ នឹងស្រពោនស្រពន់ពោរទន់ស្វោតរុះរាយលើចេរីហានតុំខាន បានសេចក្តីគណនាឧបមាបីដូចជាសាលាបរិយត្តិ បើពុំបានរុងរឿងតទៅ ព្រះពុទ្ធសាសនាក៏សឹងវិនាសបន្តិចៗម្តងពីនគរខ្មែរយើង ហេតុនេះយើងគប្បីពិចារណាឲ្យបានផ្ចូរផង់ឆ្ងាយទូលាយ នឹងបានឃើញយល់នូវប្រយោជន៍របស់សាលានេះ បុគ្គលណាមួយមានចិត្តសទ្ធាជួយជ្រោមជ្រែងសាលាបាលី បុគ្គលនោះ ខ្ញុំហ៊ានពោលថា បានធ្វើបដិបត្តិបូជាដល់សម្តេចព្រះជិនស្រីម្ចាស់លោក ។

ក្នុងច្បាប់នាគ្រប់ប្រទេសគ្រប់ដំបន់ ដែលសម្រាប់ប្រៀនប្រដៅបណ្តាក្សត្រ នោះគេតែងរំឭកដល់ធម៌សាមគ្គីសមគ្គាគី សេចក្តីព្រមព្រៀងគ្នាក្នុងកិរិយាធ្វើការទីមួយៗ សេចក្តីព្រមព្រៀងគ្នានាំមកនូវសេចក្តីសុខបណ្តាលសេចក្តីចម្រើនឲ្យកើតឡើង ធម៌នេះអ្នកប្រាជ្ញរាជបណ្ឌិតក្នុងខេមរមណ្ឌលពុំសូវមាន គួរណាស់គិតឃើញថាអាត្មាអញពុំស្គាល់ធម៌វិន័យឲ្យបានអស់លក្ខណៈទេ មានគេឯទៀតដែលគេបានសិក្សាច្រើនចេះជាងអាត្មាអញ គួរអញគប់គានគេដើម្បីនឹងបានសង្គ្រោះ ជួយជ្រោមជ្រែងពួកខ្មៅល្ងង់កុំឲ្យអវិជ្ជាមកគ្របសង្កត់ពេក អ្នកប្រាជ្ញណាគិតបែបនេះខ្ញុំពោលថាអ្នកប្រាជ្ញនោះបានធ្វើបដិបត្តិបូជាហើយ ដល់ព្រះដ៏មានបុណ្យអនន្តគុណជាម្ចាស់លើត្រៃភព ។

ពុទ្ធសាសនិកជនទាំងអស់សិក្សាធម៌វិន័យ អំពីសំណាក់សាស្តាចារ្យផ្សេងៗគ្នា មានគ្រូអាចារ្យខ្លះក៏ចេះអាថ៌ធម៌ជ្រៅជ្រះជម្រះមន្ទិលសង្ស័យបាន មានខ្លះចេះស្តួចស្តើង ហើយតម្កើងដំឡើងស័ក្តិខ្លួនអ្នកចេះដឹងពហុសូត្រ ប្រឹងប្រដៅឲ្យកូនសិស្សប្រតិបត្តិតាមក្បួនខ្នាតកម្មៅរបស់ខ្លួន ដួនត្រូវដួនខុស ចំណែកខាងកុលបុត្រវិញ ក៏ប្រឹងតែជឿគ្រូអស់ពីពោះ អួតប្រាប់គេថាគ្រូអាត្មាចេះណាស់ ដួនកាលប្រព្រឹត្តលើខុសបង់ ប្រកាន់ថាជាត្រូវតម្រូវតាមឱវាទគ្រូបាធ្យាយ កុលបុត្រធ្វើបែបនេះ កុលបុត្រនោះ ឈ្មោះហៅថាធ្វើបញ្ញាពុំមានឲ្យរស្មី ហៅថាមនុស្សគ្មានតេជក៏បាន កុលបុត្រទាំងអស់គ្នាត្រូវគិតឲ្យឃើញថា ពាក្យឯណាដែលពោលទៅហើយ នាំនូវសេចក្តីសុខដល់រូបអ្នកដទៃ និងរូបអាត្មា ពាក្យនេះជាពាក្យត្រូវ កិរិយាធ្វើទានសីលភាវនាឯណា ១ ដែលត្រឹមត្រូវតាមពុទ្ធបញ្ញត្តិនិងពុទ្ធានុញ្ញាត គ្មានកន្តប្រឡូកប្រឡំ នឹងសាសន៍ដទៃ កិរិយានោះហៅថាកិរិយារបស់ពុទ្ធបរិស័ទពិតប្រាកដ កុលបុត្រណាគិតឃើញដូចនេះ កុលបុត្រនោះ ខ្ញុំពោលថា បានធ្វើបដិបត្តិបូជាដល់ព្រះបរមគ្រូលោកនាថសាស្តាលើទេវតាមនុស្សយក្ខទាំងឡាយ ។

កុលបុត្រអ្នកអាងប្រកាន់ដោយរៀងខ្លួន នូវគ្រូអាចារ្យនាំបំបែកបែកទៅពួក ម្ល៉ោះហើយសាមគ្គីសាមគ្គាមានទៅដោយពួកដោយកង ដូចជាបណ្តាក្រស្តចិន មិនទូទៅ មិនចេះស្រឡាញ់រាប់អានអ្នកនៅក្នុងម្លប់

សាសនាជាមួយ  ធ្វើបែបនេះហៅថាមនុស្សពុំចេះស្រឡាញ់ជាតិ  បើប្រសិនណាជ.យើងនាំគ្នាធ្វើតាមទំនើងចិត្តរបស់យើង ដូចនេះ តរៀងទៅព្រះពុទ្ធសាសនានឹងវិនាសអន្តរធានដោយសារដៃរបស់យើងពុំខាន  ខ្ញុំសូមលើកវត្ថុនិទានមួយមកអធិប្បាយជូនមហាសប្បុរសទាំងអស់គ្នា គ្រាន់ជាទីសណ្តាប់  តទៅកាលក្រោយៗទៀត ។

សេចក្តីអធិប្បាយថា  កាលពីអតីតប្រព្រឹត្តកន្លងទៅហើយមានពាណិជ ១០០ នាក់ នាំទំនិញទៅលក់  បើកគេត្រាឆ្ពោះទៅកាន់នគរមួយ  លុះគេត្រាបានដល់កណ្តាលមហាសមុទ្រកាលណា  ក៏កើតហេតុវិវាទឈ្លោះគ្នា  ក្នុងវិធីគិតប្រាក់ចំណូលចំណាយ  ម៉្លោះហើយពួកពាណិជក៏ពុំបានសេចក្តីសុខរៀងខ្លួនឡើយ  ខ្លះចូលចិត្តថា  គួរនាំទំនិញបកត្រឡប់មកគេហស្ថានវិញ  ខ្លះថាគួរនាំទំនិញទៅលក់ឲ្យអស់សិនទើបនឹងគិតគ្នាជាក្រោយទៀត  ប្រកែកជជែកគ្នាទៅវិញទៅមក  ទោសគំនឹងក៏មានឡើងរាល់ខ្លួន  អ្នកខ្លះស្ទុះទៅសំរូតក្តោងផ្តាច់ខ្សែសាវ៉  អ្នកខ្លះបែរគេត្រាទៅកាន់ខាងមុខ  អ្នកខ្លះបែរចំពោះថយមកក្រោយ  គេត្រាទៅណា  ក៏ពុំរួចលុះព្រះអាទិត្យជិតអស្តង្គតវេលាណា  ពួជំកាលនោះមានព្យុះពាយុ១យ៉ាងធំ មកបក់ផាត់សំពៅនោះធ្លុះធ្លាយលិចទៅ  ឯពួកពាណិជទាំង ១០០ នាក់  ក៏បានទៅជាចំណីរបស់ត្រីធ្លាម ម្កា ពិទូង  ក្នុងមហាសមុទ្រជ្រៅ ។

សប្បុរសស្តាប់រឿងចុះ  ឯសំពៅនោះ  មានឧបមាប៊ដូចជាព្រះពុទ្ធ

សាសនា ពួកពាណិជទាំង ១០០ នាក់ ដូចជាពុទ្ធសាសនិកជនពល់គ្នា បញ្ញើដូចជាកិរិយាប្រតិបត្តិដល់ធម៌និងវិន័យ បើប្រសិនណាជាយើងគ្មានសេចក្តីរាប់អានគ្នានឹងគ្នា រកគន្លងពិតរបស់ពុទ្ធភាសិត ប្រព្រឹត្តតែគិតរកហេតុបង្កើតរឿងសាសនា ព្រះសក្យមុនីគោតមបរមគ្រូ និងវិនាសធាប់ដូចជាកេត្រារបស់នាយពាណិជ ឯរូបអាត្មាយើងរកសេចក្តីសុខបានមកពីបខណា ក្តីផងលោកនឹងបរលោកនាយ យើងសោយទុក្ខវេទនាដូចនាយពាណិជ ក្នុងពោះសត្វត្រីក្នុងសមុទ្រ ។

ខ្ញុំពន្យល់អំពីរបៀបធ្វើព្រះពុទ្ធសាសនា ឲ្យចម្រើនឡើងពុំទាន់បរិបូណ៌អស់សេចក្តីនៅឡើយ ប៉ុន្តែខ្ញុំសូមសន្មតតាត់ថាជាចប់ចុះ តាមសម័យខ្ញុំមានពេលខ្វះពេកណាស់ ប៉ុន្តែមុនឈប់អធិប្បាយនេះ ខ្ញុំសូមធ្វើបណាម ១ រំឭកដល់ព្រះករុណាស៊ីសុវត្ថិ បរមកជាទុកោដ្ឋ និងដល់គុណវិសេសរបស់ព្រះរាជបណ្ណាល័យជាបទឃោងខាងក្រោមនេះ ។

អហំតាំងថាខ្ញុំ សូមបង្គំដោយហត្ថា ដល់ព្រះមហាករុណា ក្សត្រខត្តិយាស៊ីសុវត្ថិ ។ បរមកជាទុកោដ្ឋ ព្រះទ័យសោតល្អសែនថ្លាត់ព្រះបញ្ញាថ្កាត់ បានតាក់តែងតែងសាសនា ។ បង្កើតបណ្ណាល័យជានិស្ស័យនៃបណ្ឌា ពុទ្ធបរិសទ្យា នាំបញ្ញាញាណសម្ភារ ។ ព្រះរាជបណ្ណាល័យ វិស័យក្រៃក្រែតណែនា ផ្សាយធម៌វិន័យា កើនលាភាជនទាំងឡាយ ។ ប្រៀបធៀបដូចព្រះបទ្ម រះជាក់ស្បាក់ស្រស់ក្បោះក្បាយ

កណ្ដាលស្រុកយើងអាយ កើតសប្បាយកាយមហិមា ។ កម្ចាត់បំបាត់សោក ទាំងទុយអោកកេតអវិជ្ជា ចេះស្គាល់ផលធម្មា វិន័យាត្រឹមត្រូវត្រង់ ។ សាសនាព្រះសម្ពុទ្ធ ពៅពោមមុដល្អកន្ទង ទឹងបានធំចម្បង ដូចបំណងអ្នកសទ្ធា ។ សូមតេជៈជ័យជោគ មានដល់លោកអ្នកកល់គ្នា ដែលកបដួងទ័យា ជួយព្យាបាលបណ្ណាល័យ ។ ទិញសៀវភៅសូត្ររៀន ទុកខ្ចីគ្នានប្រៀនដូនចៃ ឲ្យស្គាល់កល់តម្លៃ វចនៈថ្លៃព្រះសាស្ដា ។ សព្វទុក្ខទឹងសព្វសោក ទាំងសព្វរោគដំហានក្ដា កុំបីពាល់កាយា ដល់មហាជនកល់អង្គ ។ ទេវតាក្នុងលោកធាតុ សូមខ្ញីឃ្លាតធៀតតម្រង់ ធ្វើសាសនាឲ្យត្រង់ ត្រូវគន្លងទំនងខ្នាត ។ ធ្វើចិត្តអស់សត្វលោក ពុំស្មោកគ្រោកខំឧហាត រៀនសូត្រសិល្បសាស្ត្រ សង្អាតគិតការអ្វីល្អហើយ ។

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(ត)

---

ចូរមានបន្ទូលមកមើល តែអាណិតកុំតែបញ្ចេញសេចក្តីគិតទាស់មកទៀត ទូលបង្គំនឹងរំងាប់ឲ្យផ្ទុំលក់បាន ។

ទុរយោធន៍ថា ទ្រង់មិនឃើញឬវេលាល្ងាចយើងទន់ប្រៀបជាងគេពល់ៗ គ្នាថ្ងៃ ភីស្មៈអើយ សេចក្តីបំណងប៉ងយកជ័យជម្នះអាស្រ័យកម្លាំងទាហានរបស់ទ្រង់ ដែលទ្រង់ដំណែងជាកំពូលទ័ពនៃកុរុ ពួកបាណ្ឌពៈគ្នាហានក្នុងការសឹកសង្គ្រាម គេចៀសផុតអំពីកណ្តាប់ដៃទ្រង់ដែលប្រកបដោយប្រតិពល ហើយគេប្រហារកងទាហានរបស់ទ្រង់បែកព្រាត់ពល់អន្ទើ ចូររលឹកដល់ពាក្យបដិញ្ញារបស់ទ្រង់ ដែលថានឹងគាំពារត្រកូលខត្តិយរាជក្រុងហស្តិនបុរទុក សូមទ្រង់ឲ្យអភ័យក្នុងពាក្យដែលមិនគប្បីរបស់ខ្ញុំ ថាបើក្នុងហឫទ័យរបស់ទ្រង់ ត្រូវសេចក្តីមេត្តាក្នុងពួកបាណ្ឌពចូលទៅគ្របសង្កត់សោត ក៏បូលឲ្យកណ៌ធ្វើនាទីជាអ្នកនាំទ័ពរបស់យើងជំនួសទ្រង់ចុះ នឹងបានធ្វើការឲ្យមានជ័យជម្នះជាដាច់ៗទៅ ។

គឺស្នេះដកដង្ហើមហើយថា អនិច្ចា ទុរយោធន៍សេចក្ដីបំណងបង សម្ដាល់របស់ទ្រង់ មិនជាផលប្រយោជន៍ ការសង្គ្រាមរបស់ទ្រង់ជាការគ ស្ញ៉ូវដែលខ្សត់ផល សេនារបស់ទ្រង់ស្មើដូចរបស់លេងគ្មានតម្លៃក្នុង កណ្ដាប់ដៃនៃកម្មពៀរ ខ្ញុំបានទូលប៉ុន្មានដងមកហើយថា សេចក្ដីថា ធម្មទិនឈ្មោះថា អ្នកដែលច្បាំង ដើម្បីទ្រទ្រង់នូវធម៌ មានអាវុធជាពីរ ភាគ ចំណែកឯការច្បាំងជាអធម៌ មូលកម្លាំងខ្លួនឯងបូលមកទម្លាយខ្លួន ឯង ទ្រង់ភ្លេចហើយឬកាលយើងលើកទៅវាយប្លន់យកហ្វូងសត្វពាហនៈ នៅទីវាលមច្ឆនគរក្នុងដែនវិរាដ តែអំណាចកម្លាំងក្លាហានអរជុនម្នាក់ ឯង រហ័ពលរបស់ទ្រង់ទាំងទ័ព គោងរត់ព្រាត់របស់គេ ១ ទៀតទ្រង់ ភ្លេចហើយឬ ពីដើមពួកគន្ធារពចាប់ទ្រង់បានទៅ បានអរជុនតែម្នាក់ឯង ចូលទៅកាប់គ្រៀងពន្ធនាគារដោះទ្រង់រួចមក អរជុននេះនៅមានជីវិតនៅ ក្នុងពួកបាណ្ឌពនៅឡើយគ្រានេះគេបានក្រិស្ណមកជួយ ធ្វើនាទីជានាយ សារថីរបស់អរជុន ទាំងទ្រង់ក៏ជ្រាបហើយថាក្រិស្ណ ជាបុរសជាត្រី មាន ទេវតា១ អង្គគ្រប់គ្រងខ្លួនគេ រឿងនេះក៏ប្រាកដដល់ភ្នែកយើងព្រិលៗខ្លះ ដែរទុរយោធន៍ ព្រោះអង្គទ្រង់គោងដល់ព្រហ្មលិខិតក្នុងការសង្គ្រាមគ្រា នេះហើយ គឺស្នេះនៅមានជីវិតដរាបណា គេនឹងធ្វើមុខងារនាទីរបស់គេ ដោយសត្យសុចរិត តែមរណៈរបស់គេចូលជិតណាស់មកហើយ កុំ ព្រួយឡើយការមរណៈមកដល់ហើយ សឹមឲ្យអ្នកធំណាឯទៀត ចូល

គ្រងទ័ព ជាអ្នកបញ្ជាការកងទ័ពកុរុតទៅចុះ តែខ្ញុំសុំពោះបេបញ្ជាក់ប្អូនទៀត ឲ្យទ្រង់ជ្រាបថា កុរុក្សេត្រគ្រានេះ នឹងឲ្យផលដល់អបរាជ័យរបស់បរប័ក្ស ។

លុះថ្ងៃព្រឹកឡើងមក ក៏ចេញធ្វើការតយុទ្ធគ្នាដូចថ្ងៃមុន ។ ព្រះកក្តីស្មៈក្រញូវក្រញីងខឹងក្រោធ ព្រះនេត្រលៀនក្រឡោតស្ទើរស្រក់លោហិត ដោយមកគិតដល់ពាក្យពោសរួសរបស់ទុរយោធន៍ ហេតុនោះ ថ្ងៃនេះ គេទើបប្តូរបញ្ជាំងដោយកម្លាំងពោសមិនខ្លាចស្លាប់តាំងពីព្រឹកដល់ថ្ងៃត្រង់ ពីថ្ងៃត្រង់ដល់រសៀល គ្មានអ្នកណាទឹងតទល់របុរសនេះបាន ពួកបាណ្ឌពនាំគ្នាតប្រសាចទៅខាងមុខគេដូចហ្វូងម្រឹគ វេសិកភីស្មៈដែលគ្មានអ្នកទប់ទល់បាន ក៏បរពង្រស់ពួកពារសេនាហាន ដែលនឹងដែលកំពុងត្រជាបត្រដួសទៀបស្លាប់ត្រៀបត្រាដូចគេហាល សំដៅទៅរកពួកដែលតាំងតស៊ូនឹងពួកដែលគេចរត់ទៅ គ្មានឧបណាប៉ះមុខបាន ហៀកដល់យប់យាមសន្ធ្យាពេលត្រីកាលបរមកដល់ ។

យុធិស្ឋិរអ្នកទ្រង់សីល ក៏ពោម្ខសុត្រូវព្រះហឫទ័យរពាន់ប្រមាណ ដោយបានទតព្រះនេត្រឃើញទ័យុទ្ធភូមិ ដ៏ប្រសប់ស្រោចដោយលោហិត ខ្មោចទាហាន ដែលត្រូវគេវុងស្លាប់នឹងរបួសទៀបស្លាប់ព្រោលក្រាលពាំងប្រថពី ព្រះហឫទ័យដ៏ទន់របស់ទ្រង់ស្ទើរតែទំនងទ្រាំទ្រ នឹងរបស់ដែលប្រទះឃើញដោយព្រះនេត្រពុំបាន ព្រះហឫទ័យស្រពោន ស្តេចទៅ

ទៅរកក្រិស្ណតាំងយប់ងងឹត ហើយត្រាស់ថា សង្គ្រាមដ៏ពន្ទឹកមុខគួរព្រឺ
នេះ មិនជាផលប្រយោជន៍ ការលាន់បំផ្លាញញាតិមិត្តរលំរលាយគ្មានទី
ផុតនេះ ជាកម្មរបស់ខ្ញុំ មិត្តរបស់យើងជាសត្រូវនឹងយើង ឯការ
ដែលយើងកាប់សម្លាប់គេនោះ ក៏ឈ្មោះថាយើងសម្លាប់ខ្លួនយើងហ្នឹង
ឯង បានសឹងច្បាំងកាប់សម្លាប់គ្នាឈាមជាហូរដាបតាំងម្ល៉េះមើលទៅយើង
ក៏មិនឃើញ ជាទីងងិតទៅតម្រុយនៃជ័យជម្នះនោះឡើយ ជិះជាកាល
ណាទឹងដល់នៅទីផុត ពួកកុរុក៏មិនណាយថយត្រង់ណា គេនៅមាន
ជ័យហូតមក គ្មានអ្នកណានឹងអាចទប់ទល់កម្លាំងភីស្មៈអ្នកឈ្នះគ្រប់ទិស
នេះបាន ការដំនឿយព្រួយទទេ បង់ជីវិតទៅទទេ គស្ទូទឹងកម្មនិយម
ទាហានរបស់យើងឈាមជាហូទទេ ពស្ត្ររបស់យើងលះជីវិតឲ្យយើង
ទទេ ជាតិទាំងឡាយបានលះបង់ជីវិតនឹងលោហិតរបស់គេ ដើម្បីឃើញ
ដល់យើងក៏ទេ ក្រិស្ណអើយខ្ញុំទ្រាំមិនបានហើយ ចូរឈប់ការកាប់
សម្លាប់គ្នាដោយមិនរើសមុខបុះណា ហើយក៏នឹងនាំគ្នាទៅនៅព្រៃម្តង
ទៀតចុះ ។

កាលក្រោយប្រឹក្សានឹងក្រិស្ណ យុធិស្ឋិរបានហៅប្រជុំវេលាអធ្រាត្រ
ស្ងាត់ ដើម្បីនឹងចាត់ការរឿងនោះឲ្យសានត្រាន្ត ស្រេចការប្រជុំ ទើប
ប្រាប់ប្រើនាយទាហានអ្នកមុខអ្នកការខាងបាណ្ឌព ជាច្រើនអ្នកឲ្យទៅរក
ភីស្មៈ ទូលអង្វរសុំមេត្តាករុណាក្នុងការដែលនឹងស្មេះលើកលែងធ្វើសង្គ្រាម

តទៅ លោកអ្នកចំបាំងបុកណាបានបដិសណ្ឋារទទាក់ទទួលដោយសេចក្ដីករុណាប្រណីជាបំផុតតែត្រង់រឿងសុំសេចក្ដីមេត្តាករុណានោះ គេថ្លែងតបមកវិញថា គេនៅមានជីវិតរស់នៅជកបណា ទំនងសុំច្បាំងដណ្ដើមយកជ័យឲ្យទុរយោធន៍ជកបនោះ គេបានប្រណិធានទុករឿងនេះជាមាំមួន ជាសម្ដីនៃអ្នកចំបាំង គឺគេប្រណិធានទុកថា ទំនងមិនច្បាំងកាប់សម្លាប់សឹកដែលពាលពាញ់ ឬសឹកគេមិនតស៊ូ ឬដាក់អាវុធចេញ ឬស្រែកសុំសេចក្ដីករុណា ឬសឹកដែលញាមចុះចាញ់ ឬអស់កម្លាំង ឬត្រូវអាវុធ ឬមានជាតិកំណើតជាភេទស្ត្រី ។

ពួកអ្នកមុខអ្នកការអំបាលនោះ នាំគ្នាត្រឡប់ទៅបន្ទាយវិញ ដោយសេចក្ដីរីករាយសមប្រាថ្នាប្រាប់អរជុនថា ឥឡូវនេះ មានផ្លូវសង្ឃឹមនឹងមានជ័យហើយ ដ្បិតភីស្មបានប្រណិធានទុកថា គេនឹងមិនច្បាំង នឹងបុគ្គលភេទជាស្ត្រី យើងមានមនុស្សយ៉ាងដែលថានេះម្នាក់ នៅក្នុងកងទាហានរបស់យើង លោកយល់ដូចម្ដេចសិខណ្ឌិន សិខណ្ឌិនគេកើតមកជាភេទស្ត្រី តែកាលនៅឡើយ បានប្ដូរភេទនឹងយក្សមួយ ខ្លួនគេក៏ក្លាយជាភេទប្រុស ដូច្នេះចូរឲ្យសិខណ្ឌិននៅមុខនៃកងទ័ពយើង ភីស្មឃើញក៏គង់ជាថយទៅ ពេលយើងទុកនៅឲ្យជាម្ចាស់ទ័យុទ្ធគួមដោយមិនគោងសង្ស័យ ។

អរជុនកាលបានស្ដាប់ពាក្យប្រឹក្សានេះ ក៏ក្រោធហើយស្រែកចេញមក ខ្លាំងៗថា អាម៉ាសមុខលោកអើយ អ្នកចំបាំងដ៏សុចរិតឯណាគេនឹងបន្ទាប ខ្លួនទៅ ធ្វើការលួចល្បក់ស្ទាក់កំបាំងដូច្នេះឬលាក់សេចក្ដីក្លាហានទុក ក្រោយស្ត្រី ឬកូនក្មេង យើងម្នាក់ហើយជាមិនព្រមច្បាំងដោយអាការ កំឡោចយ៉ាងនេះ យកឧបាយយ៉ាងមុខគួរអាម៉ាស់មុខ ទៅចំលាយ ភីស្មៈអ្នករកមន្ទិលគ្មាន វិធីការនេះធ្វើឲ្យខូចកេរ្ដិ៍ឈ្មោះកិត្តិយសរបស់ យើង ។

ក្រិស្ណក្រោកឈរ តបអរជុនថា វាដល់មិតសញ្ញីដោយព្រហ្មលិខិត ហើយ ថាថ្ងៃស្អែកនេះភីស្មៈទីងដួល កាលបើគេបានច្បាំងតស៊ូនឹង អ្នកដែលគេស្រឡាញ់ ដូចម្ដេចអរជុនអើយទ្រង់ក៏គោងច្បាំងតស៊ូនឹង ព្រះញាតិរបស់ខ្លួនដូច្នោះ គេបានសម្ដែងឲ្យទ្រង់ឃើញហើយ តើអ្នកក្សត្រ ចំបាំងត្រូវតែច្បាំងគ្រប់មុខសព្វទិស មិនថាសត្រូវដែលខ្លួនស្រឡាញ់ ឬសត្រូវដែលខ្លួនស្អប់ តែលមកក៏គោងលេចសងទៅវិញ ខ្ញុំសូមប្រាប់ ទ្រង់ វាគ្មានបាបកម្មអ្វីគ្រង់ដែលឲ្យសិខណ្ឌិននាំកងទាហានរបស់យើង វេលាដែលកើតគេកើតជាអ៊ុំក៏តាម ឥឡូវនេះគេជាអ្នកចំបាំងដូចគ្នានឹង ទ្រង់ ត្រូវតែឲ្យធ្វើទាំនោះបាន គ្មានឧបាយកលយោបល់គោងយ៉ាង ដែលទ្រង់គិតក្រែងនោះទេ ។

កាលបានស្ដាប់ពាក្យរំពឹកសតិដូច្នោះហើយ អរជុនក៏ចេញច្បាំង ក្នុងថ្ងៃទី ១០ មានសិខណ្ឌិនជាអ្នកទ័ពនៃបាណ្ឌពទុរយោធន៍កាលឃើញ មេទ័ពថ្មីនាំទ័ពយុធិស្ឋិរ ក៏ព្យាយាមអង្វរភីស្មៈម្ដងទៀត ដើម្បីឲ្យលះ ដំណែងមេទ័ពឲ្យគេណា ដោយទ្រង់យល់ឃើញថា ក្នុងកងការទាហាន ត្រូវតែផ្លាស់មេទ័ពជាដរាប ទ្រង់យល់ថា មេទ័ពតែម្នាក់នាំទាហានចេញ ច្បាំងរាល់ៗថ្ងៃ មិនផ្លាស់ខ្លះដូច្នោះ ជាការប្រាប់សេចក្ដីថា ខាងខ្លះ មេទ័ពដែលខ្លាំងពូកែក្នុងកងទ័ពគុរុ ទ្រង់ឃើញថា ការផ្លាស់ទ័ពមិន ត្រឹមតែធ្វើឲ្យសម្រេចចិត្តពលទាហានប៉ុណ្ណោះ នៅធ្វើឲ្យពួកស[illegible]ក ថ្វៃដៃមេទ័ពថ្មីនោះផង កាលទ្រង់ឃើញពួកបាណ្ឌពរើសមេទ័ពជាថ្មី ទ្រង់ ក៏ចង់ដំណើរតាមយ៉ាងគេ ទ្រង់ឃើញថា ដែលធ្វើដូច្នោះ ជាអាការ សម្ដែងថា ទ្រង់នៅមានសេចក្ដីស្មើមុខនឹងសឹក ទើបទ្រង់អង្វរភីស្មៈម្ដង ទៀត ឲ្យប្រគល់ដំណែងនោះឲ្យគេណាតែភីស្មៈតបជាចំអកហាក់ថាថ្ងៃនេះ ទឹងក្រោមពួកបាណ្ឌពឲ្យរាបទាល់តែបាន ប្ដូមិនទេក៏ស្លាប់ក្នុងទីយុទ្ធភូមិ ប៉ុណ្ណោះ កុំបាច់រខានព្រះហឫទ័យនៅឡើយ ការសមប្រាថ្នារបស់ព្រះ អង្គនោះនៅមិនឆ្ងាយទេ ។

ពោលពាក្យអម្បាលនេះហើយ វីរបុរសជកក៏បររថស្ដាចេញទៅ ពោលឡកឡើយឲ្យអរជុន អ្នកច្បាំងទាំងពីរប្រាណក៏ចាប់តស៊ូគ្នាដូចពាយុ ព្យុះសង្គ្រាមពីកាលណាមកមិនដែលមានដូចយ៉ាងនេះភីស្មៈនិងអរជុន១ គូ

នេះជាអ្នកចម្បាំងឯក  រកបុគ្គលប្រៀបគ្មាន  គេតស៊ូគ្នាគ្រានេះបញ្ចេញស្នៀតគ្រប់យ៉ាង  មុខគួរមើលជាបំផុត  ពួកពាហានទាំងសងខាងជាច្រើនពាន់  នាំគ្នាមកឈរជុំកង់ជុំវិញទីនោះ  ដើម្បីមើលការតស៊ូរវាងវីរបុរសទាំងពីរ ។

កាលការតស៊ូគ្នាដល់កម្រិតជាន់ខ្ពស់បំផុតហើយ  ខណៈនោះសិខណ្ឌិនលបលួចចូលមកវាយភីស្មៈខាងក្រោយដោយមិនដឹងខ្លួន  លុះភីស្មក្រឡេកទៅឃើញ  ក៏រឭកឃើញដល់ពាក្យបដិញ្ញាដែលថា  នឹងមិនច្បាំងតស៊ូ  អ្នកដែលកើតមកជាភេទស្ត្រី  កាលរឭកដល់សម្តីនោះហើយ ដៃរបស់គេក៏សម្រេបចុះ ធនូក៏ធ្លាក់ចុះអំពីដៃ  ភីស្មៈវេលានោះបើនឹងប្រៀបទៅ  វិស័យដូចដំបូក  ខណៈនោះស្រាប់តែកូនសររបស់អជុនក៏រត់ប្រសាចមកចាក់ដោតពង់កាយភីស្មធ្លុះសព្វអវៃ្វ ទោះបីដូច្នោះក្តីវីរបុរសជរា សក់ស្កូវសព្រោងទាំងសិរ  ក៏ឈរបង្រ្គឹងរឹងគ្រឹតលើរថបីដូចបព្វតា  លោហិតហូរស្រោចកាយអាត្មា  ឥតមានសម្តែងអាការទុរខទុកយូរបន្តិចក៏មានអាការឡេងងឹតមុខ  តែម្ងឹងក៏នៅឈរខ្ជាប់ទឹងកន្លែង  ក្នុងទីបំផុត គេដឹងខ្លួនថា  ការប្រឹងរបស់គេ  ឈ្មោះថាបានប្រឹងប្រែងហើយក៏ប្រឹងប្រែងការពារកេរ្តិ៍ឈ្មោះជាតិអ្នកយុទ្ធនារបស់គេ ដល់ទីបំផុតប៉ុណ្ណោះហើយ  គេក៏ដួលចុះកណ្តាលសមរយុទ្ធនា  ដួលយ៉ាងក្សត្រិយ៍ជាតិ

អ្នកចម្បាំងតាំងតែចូលកាន់ស្នាមយុទ្ធតស៊ូសឹកសត្រូវ គ្មានល្ហែរហូតដល់ទីបំផុតនេះ ឥតបួរឥតមានដកដង្ហើមធំ ទាំងមិនព្រមឱ្យអ្នកណាដកព្រួញផ្លែដែលដោតទីទ្រូងប្រុងប្រាណនោះចេញ ចុមមុកតាំងពួកគ្រែរងកាយដេក ។

កីស្មៈកំពូលពល ដេកទាំងព្រួញផ្លុះយ៉ាងនេះ ក្នុងទីយុទ្ធភូមិ ព្រះសុរិយនក៏ទន់ទាបបិទបាំងបច្ចតា ជូនតាកកំរើងរះព្រោងព្រាយក្នុងអម្ពរ បញ្ចេញរស្មីត្រជាក់ទន់ៗមកសម្ផស្សម្បុរ ដ៏ស្រស់របស់លោកយមទ័ពដែលដួលនោះ ។

អ្នកចម្បាំងដកដេកយ៉ាងសង្ហា ព្រមដោយយសទឹងបរិវារ គ្មានឯណាកចិត្តទៅចាប់ទឹងសេចក្ដីឈឺ ពេលកលក្នុងកាយជាអារម្មណ៍សោះ បានសន្ទនាប្រាស្រ័យរកយទឹងអ្នកទាំងពួងដែលទៅគោរពមជុំខ្លួន ដើម្បីសម្ដែងសេចក្ដីសោកស្រណោះអ្នកកាន់ទុក្ខទាំងពួង រួមទាំងអាជុនទឹងយុធិស្ឋិរ ក៏កប់ចូលក្នុងចំនួននោះដែរ ទុរយោធន៍ព្រមទាំងបងប្អូនរបស់ព្រះអង្គ បានស្ដេចប្រញាប់មកកាន់ទីនោះ សន្សឹម ៗ ចូលទៅប្រជាប់ខាងអ្នកចម្បាំងដែលដួល ដួលតែមិនទាន់ស្លាប់ ។

កីស្មៈប្រាស្រ័យរកយទឹងទុរយោធន៍មុន ព្រោះហេតុថាយកន្សល់ពលិពោធទឹកតែទុរយោធន៍ប៉ុណ្ណោះជាងគេ ទ្រង់ឱ្យទុក្ខទុរយោធន៍ជាច្រើនយ៉ាងដោយតម្រិះថា បច្ចិមកាលរបស់គេក្នុងគ្រាចំផុតនេះ ប្រហែល

ជាធ្វើឲ្យចាប់ចិត្តចាប់ផ្តើមដំបើងរឿងរបស់ទុរយោធន៍ ជាងដែលហើយ មកហើយ ទើបថ្លែងសុន្ទរកថាថា ចូរស្តាប់ពាក្យខ្ញុំក្នុងកាលឥឡូវនេះ ទុរយោធន៍អើយ ចូលពាក្យបណ្តាំមុនស្លាប់របស់ញាតិអ្នកកក្តី ជាបើទ្រង់នៅមានព្រះហឫទ័យសំវេគវេទនាខ្លះដែរសោត ក៏ចូរឲ្យលើកលែងកាប់សម្លាប់ពពួកញាតិដោយដៃរបស់ខ្លួនទេះចេញ ក្សត្តិយអើយ ចូរទុកជីវិតបណ្តាក្សត្រិយ៍អ្នកក្លាហានដែលជាប់តាមព្រះអង្គមកក្នុងរាជការកម្រាបសឹកសង្គ្រាម ក្នុងយាមសុខនឹងយាមទុក្ខ កុំឲ្យជាតិកុរុដ៏ក្លានេះសាបសូន្យទៅឡើយ ចូរបង្វិលអាណាចក្រឥន្ទ្របថដ៏ជារបស់គេដោយយុត្តិធម៌នោះ ឲ្យដល់យុធិស្ឋិរអ្នកទ្រង់សីលបរិសុទ្ធ នឹងទ្រង់សត្យរកពីដំនៀលមិនបានវិញ សុំឲ្យពួកកុរុនឹងបាណ្ឌវនៅជាសុខ នឹងជាមិត្រភាពផងគ្នាមួយគ្រាទៀតចុះ នេះជាពាក្យសុំគ្រាទីបំផុតរបស់ខ្ញុំ ។

ទុរយោធន៍មានសេចក្តីសំវេគវេទនាអាណិតលោកមេទ័ពអ្នកទៀបមរណនេះណាស់ណាតែបច្ឆិមវាចារបស់លោកមេទ័ពនោះជាអសារ ឥតការក្នុងកោមលហឫទ័យទុរយោធន៍មិនទទួលអើឡើងផង ព្រះហឫទ័យទ្រង់បង្អោនទៅ តែក្នុងការលាងពួកបាណ្ឌវឲ្យរលីងទៅហើយនឹងកាន់របយកអាណាចក្ររបស់គេហេតុដូច្នោះ ទ្រង់តាំងព្រះហឫទ័យនឹងធ្វើសង្គ្រាមតទៅ ស៊ូតាល់សល់ទាហានតែម្នាក់កាន់ធ្នូស៊ូអាវុធសស្ត្រាទើបឈប់ ។

ខណៈនោះ កណ៌ក៏ចូរមករកបុរសអ្នកទៀបមរណ កណ៌មិនចូល

ចិត្តនឹងភីស្មៈ  នឹកឫស្យាតម្រិះវិជ្ជាដ៏វិសេសរបស់គេនិងដំណែងយស សក្តិខ្ពស់ដែលគេស្ថិតក្នុងវេលានេះ  គឺជាមេទ័ពធំបង្គាប់បញ្ជាកងទ័ពក្រុងវេលានេះ  ខណៈដែលលោកមេទ័ពដកដេកចាំទទួលមច្ចុរាជ  គ្រូសម្រាប់ពាសកំភួចរឿងប្រកួតក្តួតប្ញុំគ្នា  បានមកសម្តែងពាក្យលាមិនមេត្តាចិត្ត  សឡើមៗចូលមក  ដើម្បីមិនខ្វាំងខ្ញុំចិត្តលោកមេទ័ព  ភីស្មៈបានព្យួរៈដីងដើរ  កំហៅឲ្យចូលមកជិតទូខនិយាយយ៉ាងផ្អែមល្ហែមទាំកសម្តីពេញទៅដោយស្នេហាប្រណី  ««យើងធ្លាប់ជាអ្នកប្រកួតគ្នាតាំងតែកាលណាៗមកហើយ  ឫស្យាសតិបញ្ញា  និងកិត្តិយសកេរ្តិ៍ឈ្មោះរបស់គ្នានឹងគ្នា  និងចំណងតែយកជីវិតគ្នាជាទីចូ  ក្នុងវេលានេះ  សុំអហោសិកម្មឈប់ឫស្យាព្យាបាទអាឃាតគ្នាចុះណា  យើងមានសេចក្តី ១ ខដែលនឹងបញ្ចេញឲ្យអ្នកស្តាប់  តែយើងក្រែងជីវិតរស់យើងផុតទៅមុនផ្តាំសេចក្តីបច់  តែទោះបីមេច្ចក្តី  កំនិយាយសេចក្តីស្ងាត់កំបាំងរបស់អ្នកដែលខ្ញុំបិទបាំងមកយូរហើយ  តាំពុំនេះមិនមែនជាអ្នកខ្លាំងពូកែជាងអ្នកតែយ៉ាងឯណាមួយទេ  គេមិនទទួនជាងអ្នកក្នុងវិជ្ជាចម្បាំង  ឬសក្តិត្រកូលក៏មិនខ្ពង់ខ្ពស់ជាងអ្នក  ព្រោះអ្នកក៏ជាក្សត្រិយ៍  ជាប់ខ្សែលោហិតជាមួយគ្នានឹងគេ  អ្នកឯងជាឧរសព្រះនាងកុន្តី  និងសូរ្យទេពកាលព្រះនាងប្រសូតអ្នកមក  ខណៈព្រះនាងនៅក្រមុំ  សូរ្យទេពជាជនករបស់អ្នក កាលនោះជាកុមារនោះគេយកអ្នកទៅបោលលើផែនថ្ម  ដើម្បីឲ្យស្លាប់បង់

ដើម្បីនឹងបៀបបាតសេចក្ដីអាម៉ាស់មុខ នៃមាតារបស់អ្នក គ្រានោះ មាននាយសារថីម្នាក់បានទៅប្រទះ ក៏រើសយកខ្លួនអ្នកទៅផ្ទះចិញ្ចឹមជាបុត្ររបស់គេមកដូច្នេះ អរជុនក៏ជាបងប្អូនរបស់អ្នកឯង ឯសង្គ្រាមដែលធ្វើវេលានេះ ជាសង្គ្រាមរវាងវង្សញាតិយើងហ្នឹងឯង នេះជាការមិនគប្បី អំពីនេះទៅធុរៈរបស់អ្នកដែលនឹងគប្បីនាំសង្គ្រាមទៅកាន់សេចក្ដីចប់ស្រេចអស់ទៅដោយឆាប់" ។

កណ្ណិភ្ញាក់ខ្លួន ដោយដែលក្រិស្នៈបើកសេចក្ដីស្ងាត់កំបាំងនៃជាតិកំ-ណើតរបស់ខ្លួន តែមានសេចក្ដីអំណរក្នុងត្រង់ខដែលថា គេជាកូននាយសារថីត្រកូលថោកទាបនោះ មិនពិតទៅដោយសំឡេងដំនៀលអស់នេះ នឹងគ្មានតទៅ តែអន់ចិត្តត្រង់ដែលគោរពអរជុនជាបងប្អូនក្នុងពពួកមនុស្សក្នុងសកលលោកនេះ អរជុនជាអ្នកចម្បាំងដែលគេកន្ត្រើសឫស្សាស្អប់បំផុត អរជុនជាសឹកសត្រូវនឹងគ្នា ដែលគេចង់តែក្រញិចឲ្យខ្ទេចបាត់ទៅ តាំងតែនៅកុមារតូច ចូលប្រឡងរះអាវុធគ្នា គេមានសេចក្ដីឫស្សាអរជុនច្រើន ទើបកើតជាសេចក្ដីចំណងដោយចំពោះនឹងកាច់គូសត្រូវនេះឲ្យរាបទាល់តែបាន ព្រោះហេតុនោះពាក្យក្រិស្នៈដែលសុំឲ្យគេនាំសង្គ្រាមទៅកាន់សេចក្ដីចប់ស្រេចអស់ទៅ នោះចូលទៅសម្លស្សហទ័យកណ្ណិតិចណាស់ ស្មើនឹងដែលសម្លស្សហឫទ័យទុរ-យោធន៍ដូច្នោះ ។

កីស្នះផ្ទុំតាំងព្រួញធ្វើស្កះខ្លួនយ៉ាងព្រងើយ មានអ្នកយាមរក្សាការផ្ទុំវិញ រង់ចាំដល់វេលារបស់គេខឹងដំណើរទៅតាមយថាកម្ម ។

អាស្រ័យការបន្ទឹកបណ្ដាក់ចិត្តរបស់គេ បានយ៉ាងអស្ចារ្យលោកមេទ័ពអ្នកគ្មានបាប បានរង់វេលាស្លាប់ឲ្យយូរទៅដល់ថ្ងៃពេញបូណ៌មីខាងមុខ កាលដល់អភិលក្ខិតកាលនោះ លោកមេទ័ពសម្ដេះម្ចាត់ បង្អោនចិត្តដ៏ក្លាហានរបស់គេថ្វាយព្រះជាម្ចាស់អ្នកទ្រង់សនិម

ខាងពួកគោរព បានហៅប្រជុំបក្សការសង្គ្រោះម្ដងទៀតក្នុងការប្រជុំគ្រានេះ គេបានរើសយកលោកអាចារ្យពេណជាមេទ័ពក្រុមជំនួសកីស្ន ពួកបាណ្ឌពបានជ័យជំណះនេះ ក៏ក័យហេតុថា ពេណជាអាចារ្យរបស់គេ គេឃើញបាបកម្មក្នុងការដែលធ្វើបង្គ្រោះតស៊ូនឹងគ្រូ ព្រោះកងកាយរបស់គ្រូនោះ ក្នុងសម័យផណ្ណាបុកណា រាប់អានថាជារបស់សិទ្ធិធ្វើប្រទុស្តមិនបាន ។

(មានតទៅទៀត)